# សហគមន៍ខ្មែរកម្ពុជាក្រោម – ទ្វីបអាមេរិកខាងជើង

**KHMER KAMPUCHEA KROM COMMUNITY-NORTH AMERICA**
**LA COMMUNAUTĖ DU KHMER KAMPUCHEA KROM- L'AMĖRIQUE DU NORD**


## លិខិតចូលរួមមរណទុក្ខ

## ជូន

## អ្នកស្រី ថាច់ ឆ. ថេប លោក ថាច់ ញៀប

## លោក ថាច់ ដេ លោក ថាច់ គួ និងក្រុមគ្រួសារ

សហគមន៍ខ្មែរកម្ពុជាក្រោមប្រចាំទ្វីបអាមេរិកខាងជើង សមាជិក សមាជិកា និងខ្ញុំបាទមានសេចក្ដីរន្ធត់យ៉ាងក្រៃលែងចំពោះមរណភាពរបស់**លោក ថាច់ រ៉ែក** នៅថ្ងៃពុធ ២រោច ខែ ចេត្រ ឆ្នាំច អដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី ០៤ ខែ មេសា គ.ស.២០០៧ ដោយជរាពាធ និងរោគាពាធ ក្នុងអាយុ ៥៩ឆ្នាំ នៅរដ្ឋនូជើស៊ី សហរដ្ឋអាមេរិក ។

**លោក ថាច់ រ៉ែក** បានកើតក្នុងឆ្នាំ១៩៤៨ ឆ្នាំជូត នៅភូមិផ្ទោលើ ឃុំដំបូក ៣ ស្រុកផ្ទោដាច់ ខេត្តព្រះត្រពាំង កម្ពុជាក្រោម នាសម័យអាណានិគមបារាំងត្រួតត្រាព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

យើងខ្ញុំព្រះករុណា សូមគោរពវិញ្ញាណក្ខ័ន្ធ**លោក ថាច់ រ៉ែក** នូវវិរភាព និងបូជនីយកិច្ចទាំងឡាយដើម្បីជាតិ និងសាសនា ជាពិសេសបុព្វហេតុខ្មែរកម្ពុជាក្រោម ។

សូមដួងព្រលឹង**លោក ថាច់ រ៉ែក** មកសណ្ឋិតនៅនឹងកុលបុត្រកុលធីតាខ្មែរយើងគ្រប់រូប ឱ្យមានមនសិការជាតិ ដើម្បីបន្តការតស៊ូរបស់បុព្វបុរសយើងគ្រប់ជំនាន់ ។

សូមវិញ្ញាណក្ខ័ន្ធ**លោក ថាច់ រ៉ែក** អញ្ជើញទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ទីក្រុងឡូវែល សហរដ្ឋអាមេរិក ថ្ងៃទី ០៦ ខែ មេសា គ.ស.២០០៧

**គិម ឫទ្ធី**

នាយកប្រតិបត្តិស្ដីទី

---


Website: www.khmerkromngo.org
Mailing address in the United States & Canada: P.O. Box 1836, Lowell, MA 01853 U.S.A.
E-mail: KKCpressoffice@yahoo.com